00720650

E106/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 07 / 2011
ម៉ោង (Time/Heure) : 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

---

# សេចក្តីសម្រេចលើសំណើសុំពន្យារពេលរបស់អៀង សារី

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស ស្ងវាន
Jaques VERGÈS

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក អនុលោមតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ដែលបានចេញដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។

**បានទទួល** សំណើបន្ទាន់របស់ អៀង សារី សុំពន្យារពេលវេលាកំណត់ដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាងរបស់គាត់សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង (E106) ដាក់នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១។

**បានឃើញ** វិធាន៣៩(៤)(ក) នៃវិធានផ្ទៃក្នុងដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះពន្យារពេលវេលាកំណត់តាមគំនិតផ្តួចផ្តើមរបស់ខ្លួន។

**បានឃើញ** ការឆ្លើយឆ្លងរវាងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តី អៀង សារី នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១១ ដែលបញ្ជាក់ថា អង្គជំនុំជម្រះអាចនឹងផ្តល់ការអនុញ្ញាតតាមសំណើ។

**យល់ឃើញថា** ពេលវេលាកំណត់ដាក់ឯកសារសំខាន់ៗមួយចំនួនសម្រាប់ក្រុមមេធាវីការពារក្តី អៀង សារី នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ហើយយល់ឃើញដែរថា មិនមានផលប៉ះពាល់អាចកើតចេញពីការផ្តល់តាមសំណើនេះ។

## ហេតុដូច្នេះ សម្រេច

**អនុញ្ញាតឱ្យ** ក្រុមមេធាវីការពារក្តី អៀង សារី នូវពេលវេលារហូតដល់ថ្ងៃ ច័ន្ទ ទី ០៨ ខែ សីហា ឆ្នាំ ២០១១ ដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាងរបស់ខ្លួនទាក់ទងនឹងប្រធានបទបួនដំបូង។

ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

និល ណុន

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/1/26 ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/2/12។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/4/14។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការសម្រេចបន្តថិរវេលានៃការឃុំខ្លួនគាត់បណ្តោះអាសន្ននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ D427/5/9។